# របាយការណ៍ប្រចាំឆ្នាំ

## ៣១ ធ្នូ ២០២០

# អ អិម អេ (ខេមបូឌា) ម.ក

RMA (CAMBODIA) PLC.



អ អិម អេ (ខេមបូឌា)

ផ្ទះលេខ ២៧ ផ្លូវ១៣៤ ប្រអប់សំបុត្រ ៥៥ សង្កាត់មិត្តភាព ខណ្ឌ៧មករា ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទលេខ
(៨៥៥) ២៣ ៨៨៨ ០០០ ទូរសារ (៨៥៥) ២៣ ៤២៦ ៧៥២

www.cambodia.rmagroup.net

## ចក្ខុវិស័យ

| ធនធានមនុស្ស | អតិថិជន | អ្នកផ្គត់ផ្គង់ |
|---|---|---|
| ជាមនុស្សដែលមានការលើកទឹកចិត្តខ្ពស់ និងមានការចូលរួម និងមានភាពងប់ងល់ ការទទួលខុសត្រូវ ភាពច្នៃប្រឌិត និងភាពច្នៃប្រឌិតក្នុងការស្វែងរកដំណោះស្រាយល្អបំផុតចំពោះបញ្ហារបស់មនុស្ស ដើម្បីធ្វើអោយជីវិតប្រសើរឡើង។ | អតិថិជនមានភាពសប្បាយរីករាយ ដែលត្រូវបានបំរើសេវាកម្មដោយបុគ្គលដែលទទួលបានការកោតសរសើរពីក្រុមហ៊ុន RMAC ជាមួយនឹងអ្នកជំនាញ គុណភាពផលិតផល ដំណោះស្រាយ និងសេវាកម្មអតិថិជនដែលគ្មានគូរប្រៀប។ | បណ្តាញអ្នកផ្គត់ផ្គង់អតិថិជនដែលឈ្នះដោយការគោរពគ្នា និងមានមហិច្ឆិតាចែករំលែកដើម្បីធ្វើឱ្យជីវិតកាន់តែប្រសើរឡើង។ |

## បេសកកម្ម និងតម្លៃ

អ អិម អេ ជាក្រុមហ៊ុនឈានមុខគេក្នុងវិស័យផ្គត់ផ្គង់គ្រឿងយន្តក្នុងប្រទេសកម្ពុជា

អ អិម អេ បានចូលមកក្នុងទីផ្សារប្រទេសកម្ពុជាក្នុងឆ្នាំ ១៩៩២ ក្នុងនាមជាផ្តល់ដំណោះស្រាយខាងផ្នែកពាណិជ្ជកម្មនិងក្រៅពាណិជ្ជកម្ម ក្នុងវិស័យ ហេដ្ឋារចនាសម្ព័ន្ធ ថាមពល និងដឹកជញ្ជូន

ក្រុមហ៊ុនបានរីកចំរើនយ៉ាងឆាប់រហ័សទន្ទឹមគ្នានិងការអភិវឌ្ឍរបស់ប្រទេសកម្ពុជា ហើយបានពង្រីកខ្លួនក្នុងវិស័យ យានយន្ត កសិកម្ម សំណង់ ឧបករណ៍លើកដាក់ ឧបករណ៍សម្អាត និង សេវាកម្មបន្ទាប់ពីផ្នែកលក់។

អ អិម អេ បានទទួលកេរ្តិ៍ឈ្មោះក្នុងនាមជាអ្នកចែកចាយយានយន្តនិងគ្រឿងចក្រលំដាប់ពិភពលោកដូចជា RMAC has Ford (តាំងពីឆ្នាំ ១៩៩៧), Jaguar Land Rover (តាំងពីឆ្នាំ ២០១៣) John Deere (តាំងពីឆ្នាំ ២០១១), JCB (តាំងពីឆ្នាំ ២០១០), and FUSO (តាំងពីឆ្នាំ ២០១០).



ភាពច្នៃប្រឌិត

ក្រុមហ៊ុន អ អិម អេ ទទួលបានភាពជោគជ័យទៅលើការផ្តល់ដំណោះស្រាយច្នៃប្រឌិតដែលត្រូវតាមតម្រូវការរបស់អតិថិជនយ៉ាងជាក់លាក់។



ភាពសុចរិត

ក្រុមហ៊ុន អ អិម អេ តែងតែខិតខំប្រឹងប្រែងយ៉ាងល្អបំផុតសម្រាប់អតិថិជនរបស់ខ្លួន។ អ្វីក៏ដោយដែលក្រុមហ៊ុនបានធ្វើគឺធ្វើដោយភាពត្រឹមត្រូវនិងយកចិត្តទុកដាក់។



ភាពអត់ធ្មត់

ក្រុមហ៊ុន អ អិម អេ នៅតែបន្តការវិនិយោគដ៏យូរអង្វែងនៅក្នុងអាជីវកម្មរបស់ខ្លួន ភាពជាដៃគូជាមួយអតិថិជន និងភាពស្ថិតស្ថេរនៃផលិតផល និងដំណោះស្រាយផងដែរ។

# ព័ត៌មានហិរញ្ញវត្ថុសង្ខេប

| ស្ថានភាពហិរញ្ញវត្ថុ (គិតជាពាន់រៀល) | ២០២០ | ២០១៩ |
|---|---|---|
| ទ្រព្យសកម្មសរុប | ៤១៨.៩២៩.៥៧៧ | ៤៩៥.៦២៣.៥៣៧ |
| បំណុលសរុប | ២២៩.២២១.៥២០ | ៣៧៥.៤២០.០៧៦ |
| មូលធនក្រុមហ៊ុនសរុប | ១៨៩.៧០៨.០៥៧ | ១២០.២០៣.៤៦១ |
| **ប្រាក់ចំណេញ(គិតជាពាន់រៀល) (ខាត)/** | **២០២០** | **២០១៩** |
| ចំណូលសរុប | ១.១៩៥.២៩២.៧៩៧ | ១.១៤៨.៥៨៥.៣៥៤ |
| ប្រាក់ចំណេញមុនបង់ពន្ធ(ខាត)/ | ១១០.៦០១.៧៣៧ | ១១៣.៣៩៧.៦១៨ |
| ប្រាក់ចំណេញក្រោយបង់ពន្ធ(ខាត)/ | ៩៧.០៥៨.១៦៣ | ៩០.៦២៨.៨៨៣ |
| ចំណូលផ្សេងៗសង្ខេបសរុប | ៩៥.៥៩៧.៣៩៦ | ៩១.៧០៥.៥០៤ |
| **អនុបាតហិរញ្ញវត្ថុ** | **២០២០** | **២០១៩** |
| អនុបាតសាធនភាព | ១,២១ | ៣,១២ |
| អនុបាតចរន្ត (Current Ratio) | ២,៣៤ | ១,២២ |
| អនុបាតចរន្តលឿន (Quick Ratio) | ១,៣២ | ០,៣៧ |
| **អនុបាតផលចំណេញ** | **២០២០** | **២០១៩** |
| អនុបាតចំណេញធៀបនឹងទ្រព្យសកម្មមធ្យម | ២០,៩% | ២៤,៥% |
| អនុបាតចំណេញធៀបនឹងមូលធនមធ្យម | ៦១,៧% | ១០២,៥% |
| គម្លាតចំណេញដុល (Gross Profit Margin) | ១៥,៨% | ១៦,៤% |
| គម្លាតចំណេញ (Profit Margin) | ៨,១% | ៧,៩% |

| | | |
|---|---|---|
| **អនុបាតលទ្ធភាពសងការប្រាក់** | ៨,៥៨ | ១២,៨២ |

# ក្រាបស្តីអំពីស្ថានភាពហិរញ្ញវត្ថុសង្ខេប

តារាងតុល្យការ (គិតជាពាន់រៀល) ត្រឹម ៣១ ធ្នូ ២០២០






# សមាជិកក្រុមប្រឹក្សាភិបាល



Chris Manley | ឯន សាំង | Kevin Whitcraft | Tom Whitcraft | Vichit Ith

លោក Kevin Whitcraft
ប្រធានក្រុមប្រឹក្សាភិបាល

លោក ឯន សាំង
អភិបាលប្រតិបត្តិ

លោក Tom Whitcraft
អភិបាលមិនប្រតិបត្តិ

លោក Chris Manley
អភិបាលមិនប្រតិបត្តិ

លោក Ith Vichit
អភិបាលឯករាជ្យ

## សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល

វិនិយោគិនជាទីគោរព

ក្នុងរបាយការណ៍ប្រចាំត្រីមាសមុនៗ ខ្ញុំបាទបានជម្រាបជូនអំពីរបាយការណ៍សង្ខេបស្តីពីលទ្ធផលប្រតិបត្តិការហិរញ្ញវត្ថុរបស់ **ក្រុមហ៊ុន អ អិម អេ (ខេមបូឌា) ម.ក ("ក្រុមហ៊ុន RMAC")** ស្របទៅតាមលក្ខខណ្ឌតម្រូវរបស់គណៈកម្មការមូលបត្រកម្ពុជា (គ.ម.ក)។

នៅក្នុងឆ្នាំ២០២០ ក្រុមហ៊ុន RMAC បានឃើញការលក់ និងប្រាក់ចំណេញសម្រាប់ដំណាច់ត្រីមាសទី៤ ដោយប្រាក់បានប្រចាំឆ្នាំមានចំនួន ២៩៣,១ លានដុល្លារអាមេរិក និងប្រាក់ចំណេញសុទ្ធចំនួន ២៣,៨ លានដុល្លាអាមេរិក។ បើប្រៀបធៀបទៅនឹងការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុដំណាច់ត្រីមាសទី៤ នៃឆ្នាំ២០២០ របស់យើងដែលបានចុះបញ្ជីនៅដើមខែមីនា ឆ្នាំ២០២១ ក្នុងប្រយោជន៍ដែលបានមកពីការផ្សាយសញ្ញាបណ្ណ យើងអាចទទួលបានការលើកទឹកចិត្តថ្លៃពន្ធចំនួន ១,៩ លានដុល្លារអាមេរិក ពីអាជ្ញាធរពន្ធដារនៃព្រះរាជាណាចក្រកម្ពុជា។ ដូចដែលបានបង្ហាញនៅក្នុងរបាយការណ៍ប្រចាំឆ្នាំនេះ វាបានជះឥទ្ធិពលវិជ្ជមានមកលើមូលដ្ឋានរបស់យើង។ ការលើកទឹកចិត្តលើការបង់ពន្ធនេះត្រូវបានផ្តល់ឲ្យនៅពេលចេញផ្សាយសញ្ញាបណ្ណសាជីវកម្ម នៅខែមេសា ឆ្នាំ២០២០ ប៉ុន្តែក្រុមហ៊ុន RMAC កំពុងរង់ចាំនូវការអនុម័តដ៏ត្រឹមត្រូវដើម្បីកត់ត្រាវាទុកក្នុងហិរញ្ញវត្ថុរបស់យើង។

នៅក្នុងផ្នែកអាជីវកម្ម ភាពរឹងមាំនៃប្រតិបត្តិការឆ្នាំ២០២០ របស់ក្រុមហ៊ុនបានបង្ហាញឲ្យឃើញពីសក្តានុពលរបស់ពាណិជ្ជនាមក្រុមហ៊ុនយើង បន្ទាប់ពីការគាំទ្រនៃការលក់ និងភាពជោគជ័យរបស់ក្រុមកាងាររបស់ក្រុមហ៊ុនទៅលើផ្នែករថយន្ត គ្រឿងចក្រផ្នែកកសិកម្ម និងឧស្សាហកម្មធុនធ្ងន់នៅក្នុងប្រទេសកម្ពុជាផងដែរ។

នៅអំឡុងឆ្នាំ២០២០ ការលក់ចាប់ផ្តើមពីភាពជោគជ័យបំផុតនៅក្នុងដំណាច់ត្រីមាសទី១ ដែលមានការកើនឡើងពីលើតួលេខនៃការលក់ក្នុងដំណាច់ត្រីមាសទី១ ឆ្នាំ២០១៩ ចំនួន +៥៥,២ភាគរយ ប៉ុន្តែកំណើននេះបានធ្លាក់ចុះវិញនៅក្នុងដំណាច់ត្រីមាសទី២ឆ្នាំ២០២០ រហូតដល់ចំនួន -៤០,៩ភាគរយ បើប្រៀបធៀបទៅនឹងឆ្នាំ២០១៩ ដោយសារជម្ងឺរាតត្បាតនៃកូវីដ-១៩។ យ៉ាងណាមិញក្នុងដំណាច់ត្រីមាសទី៣ឆ្នាំ២០២០ កំណើននៃការលក់មានការកើនឡើងវិញ បើទោះបីជាទាបជាងឆ្នាំ២០១៩ ចំនួន -០,៤ភាគរយក៏ដោយ។

ទោះបីជាស្ថានភាពនៃការរាតត្បាតវីរុសកូវីដ-១៩ ត្រូវបានគ្រប់គ្រងបានយ៉ាងល្អនៅក្នុងប្រទេសកម្ពុជាយ៉ាងណាក៏ដោយ ផលប៉ះពាល់ចំពោះសេដ្ឋកិច្ចប្រទេសកម្ពុជានៅតែមានភាពខ្លាំងក្លាលើវិស័យចំបងៗមួយចំនួន ដូចជាវិស័យទេសចរណ៍ វិស័យសំណង់ វិស័យកាត់ដេរ និងវិស័យបដិសណ្ឋារកិច្ច។ ការចំណាយរបស់រាជរដ្ឋាភិបាលនៅក្រសួងមួយចំនួនមានការកាត់បន្ថយចំនួន ៥០ ភាគរយបើធៀបទៅនឹងឆ្នាំមុន។

ក្រុមហ៊ុន RMAC បានចាត់វិធានការណ៍មួយចំនួនដើម្បីទប់ទល់ជាមួយនឹងបញ្ហាប្រឈមនានាក្នុងឆ្នាំ២០២០ តាមរយៈការកាត់បន្ថយសារពើភណ្ឌ និងការបម្រុងទុកនូវសាច់ប្រាក់ រួមទាំងការសន្សំសំចៃចំណាយផ្សេងៗផងដែរ។ ផលិតផលទាំងអស់នៅចុងត្រីមាសទី៤ នៃឆ្នាំ២០២០ ត្រូវបានរក្សាទុកដោយស្របទៅតាមស្តង់ដារអនាម័យខ្ពស់។ ជាមួយគ្នានេះផងដែរ ក្រុមហ៊ុននៅតែបន្តធ្វើការសម្អាតផលិតផលពីក្រុមហ៊ុនរបស់យើងដោយ

ផ្តោតលើតម្រូវការរបស់អតិថិជនក្នុងប្រទេសកម្ពុជា និង ដើម្បីឲ្យប្រាកដថា ក្រុមហ៊ុនបានផ្តល់ដល់អតិថិជននូវ បច្ចេកវិទ្យាចុងក្រោយបំផុតដែលផ្តោតសំខាន់ ទៅលើ ការកាត់បន្ថយប្រើប្រេងឥន្ធៈនិង សុវត្ថិភាពរបស់អតិថិ ជនទៅលើផលិតផលដែលបានលក់របស់ក្រុមហ៊ុន យើង។ ក្នុងឆ្នាំ២០២០ បានបើកបង្ហាញឲ្យឃើញពី ផលិតផលដូចជា៖

- The All-New Land Rover Defender
- The All-Fully Electric Jaguar iPace
- The Ford Everest 2.0L Bi-Turbo
- The John Deere 6095 (95 HoursePower)

ក្រុមហ៊ុន RMAC នឹង បន្តអនុវត្តយុទ្ធសាស្រ្តអាជីវកម្មជា ក្រុមហ៊ុនផ្គត់ផ្គង់ឈានមុខគេផ្នែកយានយន្ត សំណង់ កសិកម្ម និងគ្រឿងបរិក្ខារជំនួយ (materials handling equipment) ដែលមានស្តង់ដារលំដាប់ពិភពលោកនៅ ប្រទេសកម្ពុជា។ ក្រុមហ៊ុន RMAC បានផ្តោតសំខាន់ និង យកចិត្តទុកដាក់ជាបន្តបន្ទាប់ ក្នុងនាមជាក្រុមហ៊ុនមួយដ៏ សំខាន់នៅក្នុងសេដ្ឋកិច្ចកម្ពុជាលើការ អភិវឌ្ឍធនធាន មនុស្ស និងសមត្ថភាពគ្រប់គ្រង និងការឆ្ពោះទៅមុខក្នុងរ យៈពេលវែងរបស់ក្រុមហ៊ុនក្នុងការស្វែងយល់ពីទំនួល ខុសត្រូវលើតួនាទី សង្គម និងបរិស្ថានផងដែរ។

លើសពីនេះទៀតក្រុមហ៊ុន RMAC ជឿជាក់ថាក្នុង នាមជាពលរដ្ឋសាជីវកម្មល្អ យើងត្រូវផ្តល់ជូនសហគមន៍ វិញនូវមធ្យោបាយប្រកបដោយអត្ថន័យ ការខិតខំក្នុង សង្គមរបស់ក្រុមហ៊ុនយើងក្នុងឆ្នាំ ២០២០ រួមបញ្ចូលទាំង ការបង្កើតកម្មវិធីគាំទ្រការបណ្តុះបណ្តាលបច្ចេកទេស សម្រាប់មហាវិទ្យាល័យបច្ចេកទេសនៅកម្ពុជា និងការ បន្តអនុវត្តជំនាញបើកបររបស់ក្រុមហ៊ុន RMA-Ford សម្រាប់កម្មវិធី Life។ នៅពេលដែលយើងឈានមុខគេ



ក្នុងការលក់យានយន្តនៅក្នុងប្រទេសកម្ពុជាវាចាំបាច់ណាស់ដែលត្រូវថែរក្សាឱ្យបានល្អនូវសមិទ្ធផលនេះ ហើយអតិថិជនរបស់យើងដែលបើកបរយានយន្តរបស់

យើងកំពុងបើកបរដោយសុវត្ថិភាព ការពារមនុស្សជាទីស្រឡាញ់របស់ពួកគេនៅក្នុងរថយន្ត និងសហគមន៍ផងដែរ។

ខ្ញុំបាទតំណាងឲ្យក្រុមប្រឹក្សាភិបាល សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់គណៈគ្រប់គ្រងចំពោះការដឹកនាំ ការព្យាយាម និងការប្ដេជ្ញាចិត្ត ជាពិសេសភាពឈ្លាសវៃក្នុងការឆ្លើយតបទៅនឹងបម្រែបម្រួលស្ថានការណ៍ដ៏លំបាកមួយ
រយៈកន្លងមកនេះ។

ឆ្លៀតក្នុងឱកាសនេះដែរ ខ្ញុំបាទសូមថ្លែងអំណរគុណដល់អតិថិជនដ៏មានភក្ដីភាព និងបុគ្គលិកទាំងអស់ចំពោះការលះបង់ដ៏មិនរុញរា និងរាល់កម្លាំងកាយចិត្តដែលបានផ្ដល់ជូនដល់ក្រុមហ៊ុនយើងខ្ញុំ។

លោក Kevin Whitcraft
ប្រធានក្រុមប្រឹក្សាភិបាល

ថ្ងៃទី៣០ មីនា ឆ្នាំ២០២១

# សេចក្តីថ្លែងរបស់នាយកប្រតិបត្តិ

វិនិយោគិនជាទីគោរព

ដោយសារតែការរីករាលដាលនៃវីរុសកូវីដ-១៩ ឆ្នាំ២០២០ បានបង្ហាញថាជាឆ្នាំដ៏លំបាកបំផុតមួយនៅក្នុងប្រវត្តិសាស្រ្តរបស់ក្រុមហ៊ុន។

ប៉ុន្តែខ្ញុំនៅតែមានមោទនភាពក្នុងការដែលយើងទទួលបានលទ្ធផលល្អប្រសើរ អរគុណដល់អតិថិជនស្មោះត្រង់របស់យើងដែលមិនដែលឈប់ផ្តល់តម្លៃដល់ផលិតផល និងសេវាកម្មរបស់យើង និងសូមអរគុណចំពោះអ្នកផ្គត់ផ្គង់របស់យើងផងដែរ ដែលបាននៅជិតតម្រូវការ និងឧបសគ្គអាជីវកម្មរបស់យើង និងជាពិសេសអរគុណទៅកាន់និយោជិករបស់យើងដែលបានខិតខំប្រឹងប្រែងធ្វើការដើម្បីជួយដល់ក្រុមហ៊ុនរបស់យើងក្នុងគ្រាដ៏លំបាកទាំងនេះ។

លទ្ធផលនៃកិច្ចខិតខំប្រឹងប្រែងទាំងនេះ គឺអាចមើលឃើញយ៉ាងច្បាស់ជាមួយនឹងការកើនឡើងនៃការលក់ធៀបនឹងឆ្នាំ ២០១៩ នៅក្នុងទីផ្សាររថយន្តថ្មីដែលចុះកិច្ចសន្យានៅក្នុងប្រទេសកម្ពុជា។ ការពេញចិត្តរបស់អតិថិជនយើងបានកើនឡើងម្តងទៀត។ យើងក៏បានវិនិយោគលើគ្រឿងបរិក្ខារថ្មីៗដើម្បីផ្តល់សេវាកម្មល្អបំផុតដល់អតិថិជនរបស់យើង។

ដោយភាពរឹងមាំពីលទ្ធផលល្អទាំងនេះ យើងបានត្រៀមខ្លួនរួចជាស្រេចសម្រាប់បញ្ហាប្រឈមខាងមុខនេះ និងព្យាយាមផ្តល់ជូនបន្តនូវរថយន្តតាមតម្រូវការចុងក្រោយបំផុតនៅលើទីផ្សារ ដើម្បីកាន់តែខិតជិតទៅនឹងតម្រូវការផ្លាស់ប្តូររបស់អតិថិជន និងដើម្បីផ្តល់ជូននូវសេវាកម្មបន្ទាប់ពីការលក់។



ខ្ញុំទន្ទឹងរង់ចាំថាឆ្នាំខាងមុខនេះ ជាមួយនឹងមហិច្ឆតាដ៏ទូលំទូលាយ ជាមួយភាពជាសហគ្រិន និងភាពរហ័សរហួនពី ក្រុមហ៊ុនរបស់យើងនឹងបង្កើនការប្រកួតរបស់យើងបន្ថែមទៀតនៅក្នុងទីផ្សាររថយន្តនៅកម្ពុជា។



លោក ងន សាំង

នាយកប្រតិបត្តិក្រុមហ៊ុន អ អិម អេ ខេមបូឌា

ថ្ងៃទី៣០ មីនា ឆ្នាំ២០២១

# មាតិកា


ចក្ខុវិស័យ............ ទំព័រ១

បេសកកម្ម និងតម្លៃ ............ ទំព័រ១

ព័ត៌មានហិរញ្ញវត្ថុសង្ខេប ............ ទំព័រ២

ក្រាបស្តីអំពីស្ថានភាពហិរញ្ញវត្ថុសង្ខេប ............ ទំព័រ៤

សមាជិកក្រុមប្រឹក្សាភិបាល ............ ទំព័រ៥

សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល............ ទំព័រ៦

សេចក្តីថ្លែងរបស់នាយកប្រតិបត្តិ ............ ទំព័រ៩

ផ្នែកទី១.- ព័ត៌មានទូទៅរបស់ក្រុមហ៊ុនបោះផ្សាយ ............ ១

កព័ត៌មានអំពីក្រុមហ៊ុនបោះផ្សាយ . ............ ១

ខសកម្មភាពអាជីវកម្ម . ............ ១

គ .រចនាសម្ព័ន្ធរបស់ក្រុមហ៊ុនបោះផ្សាយ ............ ២

ឃព្រឹត្តិការណ៍សំខាន់ៗរបស់ក្រុមហ៊ុនបោះផ្សាយ ............ ២

ងស្ថានភាពទីផ្សារ ............ ៧

ចសកម្មភាពប្រកួតប្រជែង ............ ៧

ឆគ្រោងការណ៍អនាគត ............ ៧

ជកត្តាហានិភ័យ . ............ ៧

ផ្នែកទី២.- ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច ............ ៨

កលទ្ធផលប្រតិបត្តិការធុរកិច្ច រាប់ .បញ្ចូលព័ត៌មានធុរកិច្ចតាមផ្នែក............ ៨

ខរចនាសម្ព័ន្ធប្រាក់ចំណូល . ............ ៩

ផ្នែកទី៣.- ព័ត៌មានស្តីអំពីអភិបាលកិច្ចរបស់ក្រុមហ៊ុន............ ១០

ករចនាសម្ព័ន្ធក្រុមហ៊ុន ............ ១០

ខក្រុមប្រឹក្សាភិបាល ........................................................................................................ ១១

គមន្ត្រីជាន់ខ្ពស់ ................................................................................................................ ១១

ផ្នែកទី៤ព័ត៌មានស្តីអំពីការលក់ដមូលបត្រ និងម្ចាស់ភាគហ៊ុន . .................................................. ១៣

ក. ព័ត៌មានស្តីពីមូលបត្រ...................................................................................................... ១៣

ខតម្លៃមូលបត្រ និងបរិមាណនៃការលក់ ................................................................................. ១៤

គការគ្រប់គ្រងម្ចាស់ភាគហ៊ុន . (%ឬលើសពី៣០ %៣០) ........................................................ ១៥

ផ្នែកទី៥ - របាយការណ៍សវនកម្មផ្ទៃក្នុងស្តីពីប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ក្រុមហ៊ុន អ អិម អេ ខេមបូឌា ភីអិលស៊ី............................................................................................................................ ១៦

ផ្នែកទី៦ - របាយការណ៍ហិរញ្ញវត្ថុត្រួតពិនិត្យដោយសវនករផ្ទៃក្នុង.............................................. ១៨

ផ្នែកទី៧ - ព័ត៌មានស្តីពីប្រតិបត្តិការរបស់ភាគីពាក់ព័ន្ធ និងទំនាស់ផលប្រយោជន៍ ...................... ១៩

ផ្នែកទី៨ - ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង ......................................................... ២១

កទិដ្ឋភាពទូទៅនៃប្រតិបត្តិការ . ........................................................................................... ២១

ខកត្តាសំខាន់ៗដែលប៉ះពាល់ដល់ប្រាក់ .ចំណេញ .................................................................. ២៤

គ. ការផ្លាស់ប្តូរសំខាន់ៗពាក់ព័ន្ធនឹងការលក់ និងចំណូល ......................................................... ២៥

ឃ. ផលប៉ះពាល់នៃអត្រាប្តូរប្រាក់ អត្រាការប្រាក់ និងតម្លៃទំនិញ ................................................ ២៥

ង. ផលប៉ះពាល់នៃអតិផរណា ................................................................................................ ២៥

ច. គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុរបស់រាជរដ្ឋាភិបាល.................................២៥

ឧបសម្ព័ន្ធនេះ របាយការណ៍ប្បចាំឆ្នាំរបស់ក្រុមហ៊ុន អ អិម អេ ខេមបូឌា (ម.ក) របាយការណ៍អភិបាលកិច្ច សាជីវកម្មប្រចាំឆ្នាំ (បានភ្ជាប់ជាមួយរបាយការណ៍ប្រចាំឆ្នាំ)

## ផ្នែកទី១.- ព័ត៌មានទូទៅរបស់ក្រុមហ៊ុនបោះផ្សាយ

### ក. ព័ត៌មានអំពីក្រុមហ៊ុនបោះផ្សាយ

| | |
|---|---|
| ឈ្មោះរបស់ក្រុមហ៊ុនបោះផ្សាយជាភាសាខ្មែរ | **អ អិម អេ (ខេមបូឌា) ម.ក** |
| ឈ្មោះរបស់ក្រុមហ៊ុនបោះផ្សាយជាភាសាឡាតាំង | RMA (CAMBODIA) PLC |
| លេខកូដស្តង់ដារ | KH2000121A44 |
| អាសយដ្ឋាន | ផ្ទះលេខ ២៧ E1 ផ្លូវ ១៣៤ សង្កាត់មិត្តភាព ខណ្ឌ ៧ មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា |
| លេខទូរស័ព្ទ | +៨៥៥ (0) ២៣ ៨៨៣ ៨៨៨ / ១២ ៨៦៧ ៦៩៧ |
| លេខទូរសារ | +៨៥៥ (0) ២៣ ៨២៦ ៧៥២ |
| គេហទំព័រ | www.cambodia.rmagroup.net |
| អ៊ីម៉ែល | saing.ngorn@rmagroup.net |
| លេខចុះបញ្ជីក្រុមហ៊ុន | ០០០០១១២១ ចុះថ្ងៃទី ១២ ខែកញ្ញា ឆ្នាំ ២០០២ |
| លេខចុះបញ្ជីឯកសារផ្តល់ព័ត៌មាន | ០០៦៨/២០ គ.ម.ក សសរ ចុះថ្ងៃទី ០២ ខែមេសា ឆ្នាំ២០២០ |
| ឈ្មោះអ្នកតំណាងរបស់ក្រុមហ៊ុនបោះផ្សាយ | លោក ងន សាំង |
| លេខាធិការក្រុមហ៊ុន | លោក មាស សុវណ្ណ (អ៊ីមែល៖ sovan.meas@rmagroup.net) |

### ខ. សកម្មភាពអាជីវកម្ម

ក្រុមហ៊ុន RMAC គឺជាក្រុមហ៊ុនចែកចាយរថយន្ត គ្រឿងចក្រកសិកម្ម និងគ្រឿងបន្លាស់ធន់ធ្ងន់នៅក្នុងប្រទេសកម្ពុជា ហើយក៏ជាក្រុមហ៊ុនផ្តល់ការធានា និងសេវាកម្មក្រោយការលក់សម្រាប់ម៉ាកល្បីៗលំដាប់ពិភពលោករួមមានដូចជា Ford, Jaguar Land Rover, John Deere, TCM, JCB, FUSO, និង Piaggio។

ប៉ុន្មានឆ្នាំកន្លងមកនេះ ក្រុមហ៊ុនទទួលបានកេរ្តិ៍ឈ្មោះជាក្រុមហ៊ុនផ្តល់សេវាកម្មនាំចូលរថយន្ត និង ផ្តល់ដំណោះស្រាយលើសេវាកម្មផ្សេងៗដែលទាក់ទងនឹងគ្រឿងផ្គត់ផ្គង់ និងការតម្លើងដំបូងគេបង្អស់។ ក្រុមហ៊ុន RMAC គឺជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុន Clipper Holdings Limited ដែលជាក្រុមហ៊ុនមេរបស់ RMA Group ដែលមានទីស្នាក់ការកណ្តាលប្រតិបត្តិប្រចាំតំបន់នៅទីក្រុងបាងកក ប្រទេសថៃ។

## គ. រចនាសម្ព័ន្ធរបស់ក្រុមហ៊ុនបោះផ្សាយ

| ល.រ | ឈ្មោះក្រុមហ៊ុន | ប្រភេទនៃទំនាក់ទំនង | ភាគរយនៃការកាន់ភាគហ៊ុន | ស្នូលនៃអាជីវកម្ម | ថ្ងៃចុះបញ្ជីក្រុមហ៊ុន | អាសយដ្ឋាន |
|---|---|---|---|---|---|---|
| ១ | Clipper Holding Ltd | ក្រុមហ៊ុនហូលឌីង នៃ ក្រុមហ៊ុន អ អិម អេ | ៩៩,៩៩% | ក្រុមហ៊ុនកាន់កាប់ | ០៥ តុលា ២០០៧ | 31/F., Tower Two Times Square 1 Matheson Street, Causeway Bay HONG KONG |

## ឃ. ព្រឹត្តិការណ៍សំខាន់ៗរបស់ក្រុមហ៊ុនបោះផ្សាយ

<u>ការបោះផ្សាយសញ្ញាបណ្ណ៖</u>

នៅថ្ងៃទី ០៩ ខែមេសា ឆ្នាំ ២០០០ ក្រុមហ៊ុន RMAC បានចេញសញ្ញាបណ្ណសាជីវកម្មចំនួន ៨០ ពាន់លានរៀល (ស្មើនឹង ២០ លានដុល្លារអាមេរិក) ដោយតម្លៃសញ្ញាបណ្ណសុទ្ធសរុបទទួលបាន៧៦,៣៨ ប៊ីលានរៀល (ស្មើនឹង ១៨,៧៨ លានដុល្លារអាមេរិក) មានរយៈពេល ៥ ឆ្នាំ និងអត្រាគូប៉ុង ៥,៥% ក្នុងមួយឆ្នាំ។ សញ្ញាបណ្ណសាជីវកម្មទាំងនេះត្រូវបានធានាដោយស្ថាប័ន Credit Guarantee and Investment Facility (“CGIF”) ដែលជាមូលនិធិបរធនបាលមួយនៃធនាគារអភិវឌ្ឍន៍អាស៊ី។ សញ្ញាបណ្ណទាំងនេះត្រូវបានចុះបញ្ជីនៅ គ.ម.ក នៅថ្ងៃទី ៣០ ខែមេសា ឆ្នាំ ២០២០ ។



<u>មជ្ឈមណ្ឌលសេវាកម្មរថយន្ត Ford ថ្មី៖</u>

នៅក្នុងត្រីមាសទី ២ ក្រុមហ៊ុន RMAC បានបើកមជ្ឈមណ្ឌលសេវាកម្មថ្មីមួយនៅទួលសង្កែ រាជធានីភ្នំពេញ ដើម្បីបង្កើនគុណភាពសេវាកម្មរបស់យើងបន្ថែមទៀត សម្រាប់បម្រើដល់អតិថិជនរបស់ Ford ដែលកំពុងតែកើនឡើង។ ការវិនិយោគជាង ១ លានដុល្លារអាមេរិកនៅក្នុងទីតាំងសេវាកម្ម គឺជាផ្នែកមួយនៃការប្តេជ្ញាចិត្តរបស់ក្រុមហ៊ុន RMAC ចំពោះម៉ាក Ford និងដើម្បីបម្រើដល់អតិថិជនរបស់យើងដែលកំពុងកើនឡើងយ៉ាងឆាប់រហ័ស។



<u>ការដាក់បង្ហាញផលិតផលថ្មីរបស់ Ford៖</u>

នៅខែឧសភាឆ្នាំ ២០២០ រថយន្ត Ford F150 Raptor ត្រូវបានបើកដំណើរការដោយជោគជ័យនៅ Digital Launch Event ដ៏ពិសេសមួយ ជាមួយនឹងការឆ្លើយតបរបស់អតិថិជនយ៉ាងខ្លាំងក្លា និងទទួលបានការកម្មង់ទិញជាច្រើន។ លើសពីនេះទៀតនៅថ្ងៃទី ០២ ខែតុលាឆ្នាំ ២០២០ ក្រុមហ៊ុន RMAC ក៏បានបើកសម្ពោធរថយន្ត Ford Everest 2.0L Bi-Turbo ថ្មីនៅ The Premier Center Sen Sok ផងដែរ។ រថយន្ត Ford Everest គឺជាប្រភេទរថយន្តល្អបំផុតនៅក្នុងរថយន្តប្រភេទ SUV ដែលផ្តោតសំខាន់ទៅលើសុវត្ថិភាពរបស់អ្នកបើកបរនិងអ្នកដំណើរ ដោយសប្បាយរីករាយទៅនឹងការប្រើប្រាស់ប្រេងតិចជាមួយនឹងបច្ចេកវិទ្យា Bi-Turbo ចុងក្រោយគេបង្អស់។



ក្រុមហ៊ុន Ford បើកដំណើរការនូវកម្មវិធី "Ford Technology Training Program"៖

នៅថ្ងៃទី ៣១ ខែសីហាឆ្នាំ ២០២០ ក្រុមហ៊ុន អ អិម អេ ខេមបូឌា បានបើកដំណើរការកម្មវិធី "Ford Technology Training Program" នៅវិទ្យាស្ថានបច្ចេកវិទ្យាឧស្សាហកម្មដោយមានវត្តមានដ៏ថ្លៃថ្លារបស់ឯកឧត្តម ហុង ជឿន រដ្ឋលេខាធិការក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងឯកឧត្តម Patrick Murphy ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក។ គោលបំណងនៃមជ្ឈមណ្ឌលនេះគឺដើម្បីគាំទ្រដល់ការជួសជុល និងកែលម្អសិក្ខាសាលាថ្មី និងផ្តល់នូវកម្មវិធីបណ្តុះបណ្តាលបច្ចេកទេសដោយអ្នកជំនាញរបស់ក្រុមហ៊ុន RMAC ។



ការបើកដំណើរការផលិតផលថ្មីរបស់ JLR៖

នៅថ្ងៃទី ៣១ ខែកក្កដាឆ្នាំ ២០២០ រថយន្ត Land Rover Defender ត្រូវបានដាក់ឱ្យដំណើរការដោយជោគជ័យនៅឯពិព័រណ៍រថយន្ត Jaguar Land Rover Showroom Event ជាមួយនឹងការឆ្លើយតបរបស់អតិថិជនយ៉ាងខ្លាំងក្លា និងទទួលបានការកម្មង់ទិញជាច្រើន។



ការបើកសម្ពោធ Land Rover All-New Defender៖

នៅថ្ងៃទី ៣១ ខែកក្កដាឆ្នាំ ២០២០ ក្រុមហ៊ុន អ អិម អេ ខេមបូឌា បានបើកសម្ពោធជាផ្លូវការនូវ ALL New Defender ឆ្នាំ ២០២០ នៅ Jaguar Land Rover Showroom។ ក្រុមហ៊ុន អ អិម អេ ខេមបូឌា បានសម្រេចចិត្តនាំចូលរថយន្តដែលសម្តែងនៅលើផ្លូវដ៏ប្រណីតនេះមកប្រទេសកម្ពុជាដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់អតិថិជនក្នុងស្រុកក៏ដូចជាដើម្បីលើកទឹកចិត្តប្រជាជនកម្ពុជាឱ្យចាប់ផ្តើមប្រើប្រាស់រថយន្តម៉ាកថ្មីពី Jaguar Land Rover។

ការបើកសម្ពោធ Jaguar All-Fully-Electric IPACE 2020៖

នៅថ្ងៃទី ៨ ខែតុលាឆ្នាំ ២០២០ ក្រុមហ៊ុន អ អិម អេ ខេមបូឌា ដែលជាក្រុមហ៊ុនចែកចាយ Jaguar Land Rover ផ្តាច់មុខនៅកម្ពុជា បានធ្វើការសម្ពោធជាផ្លូវការនូវម៉ូ_All-Fully-Electric IPACE ម៉ូដែល ២០២០ នៅសាលពិព័រណ៍ Jaguar Land Rover Showroom។ ក្រុមហ៊ុន អ អិម អេ ខេមបូឌា បានសម្រេចចិត្តនាំចូលរថយន្តអគ្គិសនីនេះ ដោយសារតែដំណើរការ និងអត្ថប្រយោជន៍របស់វា ដូចជាការចំណាយទាប ភាពងាយស្រួល គ្មានការបំភាយឧស្ម័ន និងការបើកបរមានភាពប្លែក។

ការបើកសម្ពោធផលិតផល PIAGGIO




នាថ្ងៃទី ១ ខែឧសភា ឆ្នាំ២០២០ ក្រុមហ៊ុន អ អិម អេ បានក្លាយជាអ្នកនាំចូលផ្តាច់មុខនូវយានយន្តម៉ាក Piaggio។ ក្រុមការងាររបស់យើងបាននឹងកំពុងសហការជាមួយនឹងសហគ្រាសធុនតូចនឹងមធ្យម និង បុគ្គលឯកជន ហើយទទួលបានមកវិញនូវការសរសើពីអ្នកទាំងនោះ។ បច្ចុប្បន្ន យើងខ្ញុំកំពុងស្វែងរកតំណាងចែកចាយបន្តក្នុងប្រទេស ជាពិសេសនៅតាមខេត្ត ហើយយើងខ្ញុំកំពុងធ្វើការលើខេត្តកំពង់ចាម និងខេត្តកំពង់ឆ្នាំង។

John Deere ចូលរួមក្នុងដំណើរទស្សនៈកិច្ចរបស់នាយករដ្ឋមន្ត្រីនៅខេត្តតាកែវ៖

ថ្ងៃទី ២១ ខែកក្កដាឆ្នាំ ២០២០ John Deere បានចូលរួមក្នុងដំណើរទស្សនៈកិច្ច និងព្រឹត្តិការណ៍របស់នាយករដ្ឋមន្ត្រីនៅតំបន់ព្រៃកប្បាស ខេត្តតាកែវ ដើម្បីជំរុញការអភិវឌ្ឍន៍កសិកម្មនៅកម្ពុជា និងបង្ហាញពីសមិទ្ធិផលដែលកំពុងកើនឡើងនៅក្នុងវិស័យនេះ។ គោលបំណងសំខាន់របស់លោកនាយករដ្ឋមន្ត្រីនៃដំណើរទស្សនកិច្ចនេះគឺដើម្បីមើលការបង្ហាញគ្រឿងយន្តកសិកម្មទំនើប និងស្វែងយល់អំពីវឌ្ឍនភាពកសិកម្មរបស់ប្រទេសកម្ពុជា។ នៅក្នុងព្រឹត្តិការណ៍នេះនាយករដ្ឋមន្ត្រីបានឃើញម៉ាស៊ីន John Deere នៅលើវាលស្រែ ហើយគាត់បានពិនិត្យមើលវាយ៉ាងលម្អិតជាមួយនឹងរូបថតដ៏អស្ចារ្យដែលត្រូវបានផ្សព្វផ្សាយនៅក្នុងសារព័ត៌មានក្នុងស្រុក។



ក្រុមហ៊ុន RMAC ទទួលពានរង្វាន់ Runner-up Award ក្នុងកម្មវិធី CSR Excellence




នាថ្ងៃទី ២៤ ខែវិច្ឆិកា ឆ្នាំ២០២០ សភាពាណិជ្ជកម្មអាមេរិចបានបើកកិច្ចប្រជុំប្រចាំឆ្នាំ នៅសណ្ឋាគារ Raffles Hotel Le Royal ដែលមានអ្នកចូលរួមដូចជាលោក W. Patrick Murphy ឯកអគ្គរដ្ឋទូតប្រចាំនៅសហរដ្ឋអាមេរិក លោកជំទាវ ជា សេរី អគ្គនាយកនៃធនាគារជាតិកម្ពុជា លោក បួន សារៈមុនី រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្មគណៈអភិបាល AmCham ២០២០និងសមាជិកទាំងអស់ផងដែរ។

សម្រាប់ការទទួលពានរង្វាន់ Runner-up Award ក្នុងកម្មវិធី CSR Excellenceរបស់ក្រុមហ៊ុន RMAC ក្នុងឆ្នាំ២០២០ ក្រុមហ៊ុនបានធ្វើការចាប់ដៃគូរជាមួយ Ford Motor Company បរិច្ចាគ Ford Wildtrak ចំនួន ១០គ្រឿងដល់សកលវិទ្យាល័យផ្នែកបច្ចេកទេសចំនួនបួនផ្សេងគ្នាក្នុងប្រទេសកម្ពុជា ដែលក្នុងនោះរួមមានមជ្ឈមណ្ឌលបណ្តុះបណ្តាលការសាងសង់ និងការអភិវឌ្ឍកម្មវិធីសិក្សាសម្រាប់វិទ្យាស្ថានផ្សេងៗ។ គោលបំណងនៃការបរិច្ចាគនេះ គឺដើម្បីផ្តល់ឱកាសដល់សិស្សានុសិស្សទាំងអស់ដែលសិក្សាជំនាញបច្ចេកទេសនៅសាលាបច្ចេកទេសទាំងអស់ដែលនៅក្រោមក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរួមជាមួយនឹងសាលាបច្ចេកទេសផ្សេងទៀតនៅទូទាំងប្រទេស។

## ង. ស្ថានភាពទីផ្សារ

ទីផ្សាររថយន្តនៅកម្ពុជាសម្រាប់ឆ្នាំ ២០២០ ដោយមានការធ្លាក់ចុះ (ដក៣០%) ជាមួយនឹងការលក់រថយន្តចំនួន ៦៦.០០០ គ្រឿងទាំងរថយន្តថ្មី និងរថយន្តដែលប្រើរួច ធៀបនឹងចំនួន ៩៥.០០០ គ្រឿងដែលត្រូវបានលក់នៅឆ្នាំ ២០១៩។ ការលក់រថយន្តថ្មីបានធ្លាក់ចុះ (ដក១៧%) ជាមួយនឹងការលក់រថយន្តចំនួន ១៧.០០០ គ្រឿង ខណៈការលក់នៅលើទីផ្សារបានធ្លាក់ចុះចំនួន (ដក33%) ជាមួយនឹងការលក់រថយន្តចំនួន ៤៩.០០០ គ្រឿង។ នៅក្នុងស្ថានភាពដ៏លំបាកនេះ ក្រុមហ៊ុន RMAC បានគ្រប់គ្រងកំណើនដល់ទៅ (បូក៣,៤%) នៅគ្រប់ផ្នែកទាំងអស់។

## ច. សកម្មភាពប្រកួតប្រជែង

ការប្រកួតប្រជែងក្នុងឆ្នាំ ២០២០ មានសភាពតឹងតែងយ៉ាងខ្លាំងជាមួយនឹងឈ្មួញលក់រថយន្តដែលមានស្តុកខ្ពស់ និងបានបញ្ចុះតម្លៃយ៉ាងខ្លាំងនូវម៉ូដែលមួយចំនួន។ សង្គ្រាមតម្លៃនេះបានជះឥទ្ធិពលដល់អាជីវកម្មរបស់យើងនៅក្នុងទីផ្សារ និងជាពិសេសផ្នែក Ford ។ ទោះយ៉ាងណាប្រាក់ចំណេញដុលរបស់យើងនៅតែខ្ពស់ដោយ ១៥,៨% នៃការលក់ប៉ុន្តែបានធ្លាក់ចុះបន្តិចពី ១៦,៤% ក្នុងឆ្នាំ ២០១៩ ។

## ឆ. គ្រោងការណ៍អនាគត

ក្រុមហ៊ុនអាចនឹងវិនិយោគនាពេលអនាគតក្នុងខ្សែអាជីវកម្មថ្មីដែលទាក់ទងទៅនឹងសមត្ថភាពស្នូលរបស់ខ្លួន។

## ជ. កត្តាហានិភ័យ

ជាទូទៅឧស្សាហកម្មយានយន្ត គ្រឿងចក្រកសិកម្ម និងគ្រឿងបរិក្ខារធុនធ្ងន់ប្រឈមនឹងកត្តាហានិភ័យជាក់លាក់មួយចំនួន។ ផ្នែកមួយនៃក្រុមហ៊ុនសាជីវកម្ម ឧស្សាហកម្មទាំងនេះពឹងផ្អែកលើការផ្តល់ផលិតផលប្រកបដោយប្រសិទ្ធភាពពីរោងចក្រ និងការស្នើសុំផលិតផលដែលពាក់ព័ន្ធដល់អតិថិជនក្នុងតម្លៃសមរម្យ។

ហានិភ័យដែលកើតឡើងពីអតិថិជនគឺមានច្រើនប្រភេទ ចាប់ពីការផ្តល់ជូនកាន់តែច្រើនឡើងពីការប្រកួតប្រជែងទាញយកអត្ថប្រយោជន៍កាន់តែច្រើនពីសង្គ្រាមតម្លៃរវាងដៃគូប្រកួតប្រជែងរថយន្ត ឬត្រូវបានរឹតត្បិតដោយវិស័យធនាគារលើការទទួលបានហិរញ្ញប្បទានបុគ្គល។



ភ្នំពេញ ថ្ងៃទី២៧ តុលា ២០២០ ក្រុមហ៊ុនប្រគល់ជូនកាកបាទក្រហមកម្ពុជា ដើម្បីជួយជនរងគ្រោះដោយទឹកជំនន់



កំពង់ស្ពឺ ថ្ងៃទី២០ តុលា ២០២០ ក្រុមហ៊ុនប្រគល់អំណោយដល់ជនរងគ្រោះ ៥០០ គ្រួសាររងគ្រោះដោយទឹកជំនន់នៅខេត្តកំពង់ស្ពឺ

## ផ្នែកទី២.- ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច

## ក. លទ្ធផលប្រតិបត្តិការធុរកិច្ច រាប់បញ្ចូលព័ត៌មានធុរកិច្ចតាមផ្នែក

សមិទ្ធិផលសំខាន់ៗក្នុងត្រីមាសទី៤ នៃឆ្នាំ២០២០ រួមមាន៖

<u>ភាពឈានមុខគេក្នុងទីផ្សាររបស់រថយន្តម៉ាក Ford៖</u>

សម្រាប់ត្រីមាសទី៤ ឆ្នាំ២០២០ រថយន្តម៉ាក Ford នៅតែរក្សាភាពឈានមុខគេក្នុងទីផ្សារ ដែលកាន់កាប់ចំណែកទីផ្សារភាគហ៊ុនចំនួន ៣៣,៧% សម្រាប់យានយន្តថ្មីក្នុងអំឡុងពីថ្ងៃទី១ ខែមករា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០២០ បើប្រៀបធៀបទៅនឹង ៣៣,១% ក្នុងឆ្នាំ២០១៩។ រថយន្តម៉ាក Ford Ranger នៅតែបន្តជារថយន្តដែលលក់ដាច់ជាងគេក្នុងចំណោមទីផ្សាររថយន្តក្នុងប្រទេសកម្ពុជា។

<u>**គ្រឿងចក្រម៉ាក John Deere៖** នៅជាអ្នកនាំមុខទី២នៅក្នុងទីផ្សារត្រាក់ទ័រក្នុងប្រទេសកម្ពុជា និងរក្សាតំណែងជាអ្នកនាំមុខលើត្រាក់ទ័រធន់ធំ និងម៉ាស៊ីនប្រមូលផលនៅកម្ពុជា។</u>

### <u>លទ្ធផលហិរញ្ញវត្ថុ៖</u>

ប្រាក់ចំណូលប្រចាំឆ្នាំ ២០២០ គឺ ១.១៩៥.០ ពាន់លានរៀលដែលជាការកើនឡើង + ៤,១% បើប្រៀបធៀបទៅនឹងចំណូលឆ្នាំ ១៩១៩ ។ ប្រាក់ចំណេញពីឆ្នាំ ២០២០ បន្ទាប់ពីការបង់ពន្ធមានចំនួន ៩៧,១ ពាន់លានរៀលដែលខ្ពស់ជាងឆ្នាំមុន ៧,១% ដោយសារប្រាក់ចំនេញកើនឡើង ២,៤ ពាន់លានរៀលការថយចុះ ៩,២ ពាន់លានរៀលក្នុងពន្ធលើប្រាក់ចំណូលដែល ៨,០ ពាន់លានរៀលគឺជាការលើកទឹកចិត្តពន្ធ។ ដោយ ៥,២ ពាន់លានរៀលកើនឡើងថ្លៃចំណាយហិរញ្ញវត្ថុ។

ហិរញ្ញវត្ថុសំខាន់ៗនៅដំណាច់ឆ្នាំសារពើពន្ធមាន:

ទ្រព្យសកម្មសរុបសម្រេចបាន ៨១៩ ពាន់លានរៀលធ្លាក់ចុះ ៧៧ ពាន់លានរៀល ដោយ៖

- -១៥៤ ពាន់លានរៀល តាមរយៈការកាត់បន្ថយស្តុក (ពី ៣០៧ ពាន់លានរៀលនៅចុងខែធ្នូឆ្នាំ ២០១៩ ដល់ ១៥៣ ពាន់លានរៀលនៅចុងខែធ្នូឆ្នាំ ២០២០)
- ៨១ ពាន់លានរៀលនៃបរិមាណទាបដែលទទួលបានពីក្រុមហ៊ុនពាក់ព័ន្ធ។
- +១១៥ ពាន់លានរៀលគឺជាការកើនឡើងនៃទីតាំងសាច់ប្រាក់របស់ក្រុមហ៊ុនយើង ដែលបានពង្រឹងយ៉ាងខ្លាំងដល់ ១៥៩ ពាន់លានរៀល
- សមធម៌របស់ភាគទុនិកសម្រេចបាន ១៨៩,៧ ពាន់លានរៀលដែលជាការកើនឡើងចំនួន ៦៩.៥ ពាន់លានរៀល បើប្រៀបធៀបទៅនឹងថ្ងៃទី ៣១ ខែធ្នូឆ្នាំ ២០១៩ ។
- លំហូរសាច់ប្រាក់សុទ្ធពីប្រតិបត្តិការសម្រាប់ពេញមួយឆ្នាំ ២០២០ បង្ហាញពីដំណើរខ្លាំងនិងល្អពី ២៥៧.៥ ពាន់លានរៀលកើនឡើង ដល់ + ២៦៤,៧ ពាន់លានរៀលបើប្រៀបធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។

ការកែលម្អនេះកើតឡើងយ៉ាងសំខាន់ពីការកាត់បន្ថយស្តុក។

ក្រុមហ៊ុន RMAC បានធ្វើការវិនិយោគនូវសាច់ប្រាក់សុទ្ធចំនួន +១០,៦ ពាន់លានរៀល ក្នុងឆ្នាំ២០២០ ដោយរាប់បញ្ចូលទាំងការវិនិយោគប្រមាណជាង ៥ ប៊ីលានរៀលទៅលើការបង្កើតមជ្ឈមណ្ឌលផ្តល់សេវាកម្មរថយន្តម៉ាក Ford ថ្មី ដោយមានបំពាក់ជាមួយនូវគ្រឿងបរិក្ខារចុងក្រោយបំផុតដើម្បីអនុញ្ញាតឲ្យក្រុមការងាររបស់យើងខ្ញុំអាចផ្តល់សេវាកម្មលំដាប់ពិភពលោកជូនដល់អតិថិជនរបស់យើងខ្ញុំដែលកំពុងតែកើនឡើង។

## ខ. រចនាសម្ព័ន្ធប្រាក់ចំណូល

RMAC គឺជាក្រុមហ៊ុនចម្រុះដែលតំណាងឱ្យយីហោលំដាប់ពិភពលោកជាច្រើនរួមទាំង Ford, Jaguar, Land Rover, Fuso, John Deere និង JCB ។ ខណៈពេលដែលផ្នែកអាជីវកម្មផ្សេងទៀតកំពុងអភិវឌ្ឍអាជីវកម្ម Ford ផ្នែកគឺជាផ្នែកដ៏សំខាន់នៃរចនាសម្ព័ន្ធប្រាក់ចំណូលបច្ចុប្បន្នរបស់ក្រុមហ៊ុន។ ផ្នែកជំនួញរបស់ក្រុមហ៊ុនហ្វដត្រូវបានបង្កើតឡើងពីការលក់យានយន្តបន្ទាប់ពីសេវាកម្មលក់និងគ្រឿងបន្លាស់មានចំនួន ៨៧,២% នៃចំណូលប្រចាំឆ្នាំ ២០ (បើធៀបនឹងប្រាក់ចំណូល ៨៦,១% នៃចំណូលឆ្នាំ ១៩១) ។

ប្រាក់ចំណូលតាមផ្នែកត្រូវបានបង្ហាញនៅក្នុងផ្នែកទី ៤ នៃរបាយការណ៍នេះ។

## ផ្នែកទី៣.- ព័ត៌មានស្តីអំពីអភិបាលកិច្ចរបស់ក្រុមហ៊ុន

### ក. រចនាសម្ព័ន្ធក្រុមហ៊ុន



## ខ. ក្រុមប្រឹក្សាភិបាល

សមាសភាពក្រុមប្រឹក្សាភិបាល

| លរ. | ឈ្មោះ | តំណែង | កាលបរិច្ឆេទតែងតាំង | កាលបរិច្ឆេទបញ្ចប់អាណត្តិបច្ចុប្បន្ន |
|---|---|---|---|---|
| ១ | លោក Kevin Robert Whitcraft | ប្រធានក្រុមប្រឹក្សាភិបាល | ២៦ កញ្ញា ២០០២ | ២៨ កក្កដា ២០២២-អាស្រ័យលើការសម្រេចជាថ្មី |
| ២ | លោក Thomas Arthur Whitcraft | អភិបាលមិនប្រតិបត្តិ | ២៦ កញ្ញា ២០០២ | ២៨ កក្កដា ២០២២-អាស្រ័យលើការសម្រេចជាថ្មី |
| ៣ | លោក ងន សាំង | អភិបាលប្រតិបត្តិ និងជានាយកប្រតិបត្តិ | ២៣ មីនា ២០១៦ | ២៨ កក្កដា ២០២២-អាស្រ័យលើការសម្រេចជាថ្មី |
| ៤ | លោក Ith Vichit | អភិបាលឯករាជ្យ | ២៩ កក្កដា ២០១៩ | ២៨ កក្កដា ២០២២-អាស្រ័យលើការសម្រេចជាថ្មី |
| ៥ | លោក Christopher Gowen Manley | អភិបាលមិនប្រតិបត្តិ | ២៩ កក្កដា ២០១៩ | ២៨ កក្កដា ២០២២-អាស្រ័យលើការសម្រេចជាថ្មី |

លេខាធិការក្រុមហ៊ុន៖ លោក មាស សុវណ្ណ នាយកគ្រប់គ្រងផ្នែកច្បាប់ និងអនុលោមភាព។

## គ. មន្ត្រីជាន់ខ្ពស់

សមាសភាពមន្ត្រីជាន់ខ្ពស់



| ល.រ | ឈ្មោះ | ភេទ | តំណែង |
|---|---|---|---|
| ១ | លោក ងន សាំង | ប្រុស | នាយកប្រតិបត្តិ |
| ២ | លោក សេង រឹង | ប្រុស | ប្រធានគ្រប់គ្រងទូទៅផ្នែក Ford |
| ៣ | លោក Erwan Soubelet | ប្រុស | នាយកហិរញ្ញវត្ថុ |
| ៤ | លោក ងន សាំង (បណ្តោះអាសន្ន) | ប្រុស | ប្រធានគ្រប់គ្រងផ្នែក JLR |
| ៥ | លោក សុខ សុន្ទរ៉ា | ប្រុស | ប្រធានគ្រប់គ្រងទូទៅផ្នែកបរិក្ខារកសិកម្ម និងប្រធានគ្រប់គ្រងស្តីទីនៃផ្នែកបរិក្ខារធនធ្ងន់ |
| ៦ | លោក តាន់ អាង | ប្រុស | ប្រធានស្តីទីផ្នែកប្រតិបត្តិនៃបរិក្ខារពិសេស |
| ៧ | លោក Grant Honeyman | ប្រុស | ប្រធានគ្រប់គ្រងទូទៅផ្នែកធនធានមនុស្ស |
| ៨ | លោកស្រី សៅ សុភា | ស្រី | អ្នកគ្រប់គ្រងផ្នែកដឹកជញ្ជូន |
| ៩ | លោក មាស សុវណ្ណ | ប្រុស | លេខាធិការក្រុមហ៊ុន |
| ១០ | លោកស្រី ណាង ពិសី | ស្រី | ប្រធានផ្នែកទំនាក់ទំនងសាធារណៈ |
| ១១ | លោកស្រី សុខណារី | ស្រី | ប្រធានផ្នែកដេញថ្លៃ |

សម្គាល់៖ ព័ត៌មានលម្អិតនៃអភិបាលកិច្ចក្រុមហ៊ុនត្រូវបានភ្ជាប់ដូចនៅក្នុងឧបសម្ព័ន្ធ។

## ផ្នែកទី៤. ព័ត៌មានស្តីអំពីការលក់ដមូលបត្រ និងម្ចាស់ភាគហ៊ុន

## ក. ព័ត៌មានស្តីពីមូលបត្រ

១. ព័ត៌មានស្តីពីមូលបត្រកម្មសិទ្ធិ (សម្រាប់ក្រុមហ៊ុនបោះផ្សាយកម្មសិទ្ធិ)

- ឈ្មោះមូលបត្រកម្មសិទ្ធិ [គ្មាន]
- និមិត្តសញ្ញានៃមូលបត្រកម្មសិទ្ធិ [គ្មាន]
- ចំណាត់ថ្នាក់នៃមូលបត្រកម្មសិទ្ធិ [គ្មាន]
- តម្លៃក្នុងមួយមូលបត្រកម្មសិទ្ធិ [គ្មាន]
- តម្លៃ IPO [គ្មាន]
- ចំនួនសរុបនៃភាគហ៊ុនដែលនៅសល់ [គ្មាន]
- មូលធនទីផ្សារ [គ្មាន]
- ការអនុញ្ញាតឲ្យមានទីផ្សារមូលបត្រ [គ្មាន]

២. ព័ត៌មានស្តីពីមូលបត្របំណុល (សម្រាប់ក្រុមហ៊ុនបោះផ្សាយបំណុល)

| ព័ត៌មាន | ការពិពណ៌នា |
|---|---|
| **ប្រភេទនៃមូលបត្របំណុល** | សញ្ញាបណ្ណសាជីវកម្ម |
| **និមិត្តសញ្ញា** | សញ្ញាបណ្ណសាជីវកម្ម អ អិម អេ ខេមបូឌា ("សញ្ញាបណ្ណ") |
| **កាលបរិច្ឆេទបោះផ្សាយ** | ៩ មេសា ២០២០ |
| **ចំនួនសរុបនៃបំណុល** | ៨០ ពាន់លានរៀល (ឬ សមមូលជាប្រាក់ដុល្លារហូតដល់ ២០ លានដុល្លារអាមេរិក ដោយយកចំនួនណាដែលតូចជាង) |
| **ចំនួនសរុបនៃមូលបត្របំណុលដែលនៅសល់** | មិនមាន |
| **ឥណប្រតិទាន** | ៥ ឆ្នាំ [២០២០-២០២៥] គិតចាប់ពីកាលបរិច្ឆេទបោះផ្សាយ |
| **កាលវិភាគបង់គូប៉ុង** | ត្រូវបង់ប្រចាំឆ្នាំនៅរៀងរាល់ថ្ងៃទី ០៩ ខែមេសា ឆ្នាំ.... |
| **អត្រាគូប៉ុង(%)** | ៥,៥% ក្នុងមួយឆ្នាំ |
| **ចំនួនសរុបនៃការបង់គូប៉ុង** | មិនមាន |
| **ចំណាត់ថ្នាក់លទ្ធភាពសង (ប្រសិនបើមាន)** | សញ្ញាបណ្ណត្រូវបានធានាដោយស្ថាប័ន CGIF។ យោងតាមប្រកាសស្តីពីការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ: មិនមានលក្ខខណ្ឌតម្រូវឲ្យធ្វើចំណាត់ថ្នាក់លទ្ធភាពសងលើសញ្ញាបណ្ណសាជីវកម្មនោះទេ ប៉ុន្តែបុគ្គលធានាតម្រូវឲ្យមានចំណាត់ថ្នាក់លទ្ធភាពសង។<br>ស្ថាប័ន CGIF មានលទ្ធភាពសងដូចតទៅ៖<br>- "AA/A-1+" កម្រិតសកល (រយៈពេលវែង និងរយៈពេលខ្លី)<br>ទស្សនវិស័យស្ថេរភាព កំណត់ដោយភ្នាក់ងារវាយតម្លៃលទ្ធភាពសង S&P នៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២០ |

| | |
|---|---|
| | - "gAAA/seaAAA/AAA" កម្រិតសកល/អាស៊ាន/ជាតិ ទស្សនវិស័យស្ថេរភាព កំណត់ដោយភ្នាក់ងារវាយតម្លៃលទ្ធភាពសង RMA Rating នៅថ្ងៃទី៣០ ខែមករា ឆ្នាំ២០២០<br>- "AAA" កម្រិតជាតិ ទស្សនវិស័យស្ថេរភាព កំណត់ដោយភ្នាក់ងារវាយតម្លៃលទ្ធភាពសង MARC ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៩<br>- "AAA" កម្រិតជាតិ ទស្សនវិស័យស្ថេរភាព កំណត់ដោយភ្នាក់ងារវាយតម្លៃលទ្ធភាពសង Fitch Rating នៃប្រទេសឥណ្ឌូនេស៊ី ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៩<br>- "AAA" កម្រិតជាតិ ទស្សនវិស័យស្ថេរភាព កំណត់ដោយភ្នាក់ងារវាយតម្លៃលទ្ធភាពសង TRIS Rating ថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៩<br>- "idAAA" កម្រិតជាតិ ទស្សនវិស័យស្ថេរភាព កំណត់ដោយភ្នាក់ងារវាយតម្លៃលទ្ធភាពសង Pefindo Credit Rating Agency ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៩ |

## ខ. តម្លៃមូលបត្រ និងបរិមាណនៃការលក់

| មូលបត្រ | | មករា | កុម្ភៈ | មិនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| តម្លៃលក់ | **អតិបរមា** | [គ្មាន] | | | | | | | | | | | |
| | **មធ្យម** | [គ្មាន] | | | | | | | | | | | |
| | **អប្បរមា** | [គ្មាន] | | | | | | | | | | | |
| បរិមាណលក់ | **អតិបរមា** | [គ្មាន] | | | | | | | | | | | |
| | **មធ្យម** | [គ្មាន] | | | | | | | | | | | |
| | **អប្បរមា** | [គ្មាន] | | | | | | | | | | | |

## គ. ការគ្រប់គ្រងម្ចាស់ភាគហ៊ុន (៣០% ឬលើសពី៣០%)

| ល.រ | ឈ្មោះ | សញ្ជាតិ | ចំនួនភាគហ៊ុន | ចំនួនភាគរយ |
|---|---|---|---|---|
| ១ | Clipper Holding Ltd | ហុងកុង | ៩៩៩ | ៩៩,៩៩% |
| សរុប | | | ៩៩៩ | ៩៩,៩៩% |

## ផ្នែកទី៥ - របាយការណ៍សវនកម្មផ្ទៃក្នុងស្តីពីប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ក្រុមហ៊ុន អ អិម អេ ខេមបូឌា ភីអិលស៊ី សម្រាប់ឆ្នាំ ២០២០

### ១. សេចក្តីផ្តើម

មុខងារសវនកម្មផ្ទៃក្នុង គឺមានភាពឯករាជ្យពីផ្នែកគ្រប់គ្រងនិងប្រតិបត្តិការអាជីវកម្ម និងការធ្វើរបាយការណ៍ទៅគណៈកម្មាធិការសវនកម្មនិងហានិភ័យនៃក្រុមហ៊ុន។ ក្រុមសវនកម្មផ្ទៃក្នុងផ្តល់ជំនួយតាមតំបន់ និងក្រុមអ្នកគ្រប់គ្រងដោយអនុវត្តតាមវិធីសាស្ត្រដែលផ្អែកលើហានិភ័យដើម្បីវាយតម្លៃជាឯករាជ្យនូវប្រសិទ្ធភាពនៃការគ្រប់គ្រងផ្ទៃក្នុង និងនីតិវិធីគ្រប់គ្រងហានិភ័យ ភាពជឿជាក់លើព័ត៌មានដែលត្រូវបានប្រើសម្រាប់ការធ្វើរបាយការណ៍ និងការធ្វើសេចក្តីសម្រេចចិត្ត ការប្រើប្រាស់ធនធាន និងទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនប្រកបដោយប្រសិទ្ធភាព និងការអនុលោមតាមស្តង់ដារសាជីវកម្ម ច្បាប់ គោលការណ៍អាជីវកម្មនិងអភិបាលកិច្ច។ មុខងារសវនកម្មផ្ទៃក្នុងត្រូវបានផ្តល់ជូនដោយ ក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុន អ អិម អេ ស៊ី និង ក្រុមហ៊ុន អ អិម អេ គ្រុប ខូអិលធីឌី។

### ២. ទំនួលខុសត្រូវនៃតួនាទីសវនកម្មផ្ទៃក្នុង

តួនាទីសវនកម្មផ្ទៃក្នុងមានទំនួលខុសត្រូវដូចតទៅៈ

ក. ធ្វើរបាយការណ៍សវនកម្មផ្ទៃក្នុងទាំងអស់ និងផ្តល់របាយការណ៍ទាំងនេះទៅគណៈកម្មាធិការសវនកម្ម និងហានិភ័យ ដើម្បីពិនិត្យ វាយតម្លៃ និងបញ្ជូនទៅក្រុមប្រឹក្សាភិបាល

ខ. ផ្សព្វផ្សាយរាល់ការរកឃើញសំខាន់ៗដែលអាចជះឥទ្ធិពលដល់ប្រតិបត្តិការរបស់ក្រុមហ៊ុន អ អិម អេ ស៊ី ទៅកាន់គណៈកម្មាធិការសវនកម្ម និងហានិភ័យ ឬនាយកឯករាជ្យ។

គ. រៀបចំការប្រជុំជាមួយគណៈកម្មាធិការសវនកម្ម និងហានិភ័យយ៉ាងហោចណាស់មួយដងក្នុងមួយឆ្នាំដោយមិនមានវត្តមានថ្នាក់គ្រប់គ្រង

ឃ. អនុវត្តមុខងារផ្សេងៗទៀតដែលបានចាត់តាំងដោយ គណៈកម្មាធិការសវនកម្មនិងហានិភ័យ និងក្រុមប្រឹក្សាភិបាល និង;

ង. មុខងារផ្សេងទៀតដែលកំណត់ដោយគណៈកម្មាធិការសវនកម្មនិងហានិភ័យ និងក្រុមប្រឹក្សាភិបាល។

### ៣. សកម្មភាពសវនកម្មផ្ទៃក្នុង ឆ្នាំ២០២០

ក្រុមហ៊ុន RMAC បានផ្សព្វផ្សាយមូលបត្របំណុលដែលត្រូវបានចុះបញ្ជី CSX នៅខែមីនា ឆ្នាំ២០២០។ វិសាលភាពនៃសវនកម្មពេញលេញត្រូវបានគ្រោងទុកសម្រាប់ត្រីមាសទី២ ឆ្នាំ ២០២០ ប៉ុន្តែដោយសារការឆ្លងមេរោគកូវីដ-១៩ ការធ្វើដំណើរអន្តរជាតិបានរារាំងក្រុមសវនកម្មផ្ទៃក្នុងរបស់ក្រុមហ៊ុន អ អិម អេ គ្រុប ខូអិលធីឌី មិនឱ្យធ្វើដំណើរមកប្រទេសកម្ពុជាដើម្បីបញ្ចប់សវនកម្ម។ ដូច្នេះ ដើម្បីធានាថាសវនកម្មអាចត្រូវបានធ្វើឡើងក្នុងឆ្នាំ២០២០ វិសាលភាពនៃការធ្វើសវនកម្មត្រូវបានកាត់បន្ថយ និងបានផ្តោតលើការវាយតំលៃផ្អែកលើហានិ

ភ័យជាមួយមុខងារមួយចំនួនដែលកំពុងត្រូវបានធ្វើសវនកម្មដូចជា ហិរញ្ញវត្ថុ ឬគណនេយ្យ លទ្ធកម្ម និងការអនុលោមតាមប្រព័ន្ធគ្រប់គ្រងបរិស្ថាន និងសង្គម។ ក្រុមហ៊ុនសវនកម្មផ្ទៃក្នុងបានចូលរួមជួយបំពេញសវនកម្ម។ របាយការណ៍ផ្ទុកទៅដោយព័ត៌មានលម្អិតអំពីលទ្ធផលនៃការធ្វើសវនកម្ម ផលប៉ះពាល់នៃហានិភ័យនិងអនុសាសន៍ដើម្បីកាត់បន្ថយហានិភ័យដែលបានគូសបញ្ជាក់រួមជាមួយកាលបរិច្ឆេទគោលដៅផែនការសកម្មភាពសម្រាប់បញ្ហាដែលត្រូវដោះស្រាយ។

## ៨. សេចក្តីសន្និដ្ឋាន

នាយកដ្ឋានសវនកម្មផ្ទៃក្នុងបានធ្វើសវនកម្មលើមុខងារដែលបានរៀបរាប់ខាងលើដោយផ្អែកលើការវាយតម្លៃផ្អែកលើហានិភ័យ ហើយបានរាយការណ៍អំពីលទ្ធផលនេះទៅគណៈកម្មាធិការសវនកម្ម និងហានិភ័យ និងនាយកប្រតិបត្តិ។ចំណុចហានិភ័យជាច្រើនត្រូវបានលើកឡើងនៅក្នុងវិស័យទាំងនេះ ហើយអនុសាសន៍ដើម្បីកាត់បន្ថយហានិភ័យត្រូវបានចេញផ្សាយ ដែលតម្រូវឱ្យមានផែនការសកម្មភាពសម្រាប់កែតម្រូវកំណត់ដោយថ្នាក់ដឹកនាំក្រុមហ៊ុនដើម្បីអនុវត្តអនុសាសន៍ទាំងនោះ។

**បានអាន និង អនុម័ត**

**កាលបរិច្ឆេទ: ៣០ មីនា ២០២១**

**ហត្ថលេខា**

______________________

**ប្រធានគណៈកម្មាធិការ**

**កាលបរិច្ឆេទ: ៣០ មីនា ២០២១**

**ហត្ថលេខា**

30 MAR 2021

JANINE M. BALIOLA

______________________

**ប្រធានសវនកម្មផ្ទៃក្នុង**

## ផ្នែកទី៦ - របាយការណ៍ហិរញ្ញវត្ថុត្រួតពិនិត្យដោយសវនករផ្ទៃក្នុង

សូមយោងលើឧបសម្ព័ន្ធសម្រាប់ព័ត៌មានហិរញ្ញវត្ថុដែលបានធ្វើសវនកម្មសម្រាប់ឆ្នាំហិរញ្ញវត្ថុដែលបានបញ្ចប់នៅ ថ្ងៃទី ៣១ ខែធ្នូឆ្នាំ ២០២០

## ផ្នែកទី៧ - ព័ត៌មានស្តីពីប្រតិបត្តិការរបស់ភាគីពាក់ព័ន្ធ និងទំនាស់ផលប្រយោជន៍

ក្រុមហ៊ុនបោះផ្សាយត្រូវបង្ហាញឯកសារព័ត៌មានស្តីពីប្រតិបត្តិការ ភាគីដែលពាក់ព័ន្ធនៅកំឡុងពេលពីរឆ្នាំចុងក្រោយ បញ្ជាក់ឈ្មោះ ទំនាក់ទំនងរវាងក្រុមហ៊ុនបោះផ្សាយ និងភាគីពាក់ព័ន្ធ ទំហំនៃប្រតិបត្តិការ និង ប្រភេទនៃការប្រាក់ដែលកើតចេញពីទំនាក់ទំនងដូចខាងក្រោម:

ក. ឯកសារប្រតិបត្តិការជាមួយម្ចាស់ភាគហ៊ុនដែលកាន់ភាគហ៊ុនយ៉ាងតិច៥% (ប្រាំភាគរយ) ឬច្រើននៃចំនួនមូលបត្រកម្មសិទ្ធិដែលនៅសល់

សូមមើលលើឧបសម្ព័ន្ធសម្រាប់ព័ត៌មានហិរញ្ញវត្ថុដែលបានធ្វើសវនកម្មសម្រាប់ឆ្នាំហិរញ្ញវត្ថុឆ្នាំ ២០២០ ចំនុច ២៦ "ភាគីពាក់ព័ន្ធ"

ខ. ឯកសារប្រតិបត្តិការជាមួយអភិបាល និងមន្ត្រីជាន់ខ្ពស់

សូមមើលលើឧបសម្ព័ន្ធសម្រាប់ព័ត៌មានហិរញ្ញវត្ថុដែលបានធ្វើសវនកម្មសម្រាប់ឆ្នាំហិរញ្ញវត្ថុឆ្នាំ ២០២០ ចំនុច ២៦ "ភាគីពាក់ព័ន្ធ

គ. ប្រតិបត្តិការជាមួយអភិបាល និងម្ចាស់ភាគហ៊ុនពាក់ព័ន្ធដើម្បីទិញឬលក់ទ្រព្យសម្បត្តិ និងសេវាកម្ម

មិនមាន

ឃ. ឯកសារប្រតិបត្តិការជាមួយសមាជិកគ្រួសាររបស់អភិបាល មន្ត្រីជាន់ខ្ពស់ និងម្ចាស់ភាគហ៊ុនដែលកាន់ភាគហ៊ុនយ៉ាងតិច៥% (ប្រាំភាគរយ)ឬច្រើន

មិនមាន

ង. ឯកសារប្រតិបត្តិការជាមួយបុគ្គលដែលជាប់ទាក់ទងនឹងអភិបាលនៃក្រុមហ៊ុនបោះផ្សាយ ក្រុមហ៊ុនបុត្រសម្ព័ន្ធឬក្រុមហ៊ុនកាន់កាប់ដែលមានទំនាក់ទំនងនៅក្នុងប្រតិបត្តិការណាមួយ ឬបានធ្វើឡើងដោយក្រុមហ៊ុនបោះផ្សាយ

សូមមើលលើឧបសម្ព័ន្ធសម្រាប់ព័ត៌មានហិរញ្ញវត្ថុដែលបានធ្វើសវនកម្មសម្រាប់ឆ្នាំហិរញ្ញវត្ថុឆ្នាំ ២០២០ ចំនុច ២៦ "ភាគីពាក់ព័ន្ធ

ច. ឯកសារប្រតិបត្តិការជាមួយអតីតអភិបាល ឬបុគ្គលដែលបានចូលរួមជាមួយអតីតអភិបាល

មិនមាន

ឆ. ឯកសារប្រតិបត្តិការជាមួយអភិបាលដែលកំពុងកាន់តំណែងនៅក្នុងអង្គការគ្មានប្រាក់ចំណូល ឬនៅក្នុងក្រុមហ៊ុនផ្សេងៗទៀតក្រៅពីក្រុមហ៊ុនបោះផ្សាយ

មិនមាន

ជ. ឯកសារប្រតិបត្តិការជាមួយនាយកដែលទទួលបានចំនួល ឬមិនបានចំណូលពីក្រុមហ៊ុនបោះផ្សាយ

សូមមើលលើឧបសម្ព័ន្ធសម្រាប់ព័ត៌មានហិរញ្ញវត្ថុដែលបានធ្វើសវនកម្មសម្រាប់ឆ្នាំហិរញ្ញវត្ថុឆ្នាំ ២០២០ ចំនុច ២៦ "ភាគីពាក់ព័ន្ធ

## ផ្នែកទី៨ - ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង

### ក. ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ

### ១. ការវិភាគចំណូល

ចំណូលសរុប មានចំនួន ១.១៩៦ ប៊ីលានរៀល សម្រាប់ ឆ្នាំ២០២០ ដែលបានកើនឡើងចំនួន +៤,១% បើធៀប ឆ្នាំ២០១៩ មានប្រាក់ចំណូលចំនួន ១.១៤៨,៦ ប៊ីលានរៀល ដែលសបញ្ជាក់អោយឃើញពីភាពរឹងមាំនៃត្រីមាសទី ១ ឆ្នាំ ២០២០ ស្របជាមួយនឹងការធ្លាក់ចុះក្នុងត្រីមាសទី២ ឆ្នាំ២០២០ (ចំនួន -៤០,៩% ទាបជាងការលក់ក្នុងត្រីមាសទី២ នៃឆ្នាំ២០១៩) ដោយសារការរាតត្បាតនៃវីរុសកូវីដ-១៩។ ប្រាក់ចំណូលក្នុងត្រីមាសទី៣ ឆ្នាំ២០២០ ដែលមានការកើនឡើងជាបន្តបន្ទាប់ ថ្វីបើតួលេខសម្រាប់ត្រីមាសទី៣ ឆ្នាំ២០២០ មានភាពទាបជាងត្រីមាសទី៣ ឆ្នាំ២០១៩ (ចំនួន -0,៤%) ហើយចំពោះប្រាក់ចំណូលត្រីមាសទី៤ ឆ្នាំ២០២០ មានចំនួន ២០,៧% ខ្ពស់ជាងត្រីមាសទី៤ ឆ្នាំ២០១៩។

### ២. ផ្នែកនៃចំណូល

| គិតជាពាន់រៀល | ២០២០ | ភាគរយនៃភាគហ៊ុន | ២០១៩ | ភាគរយនៃភាគហ៊ុន |
|---|---|---|---|---|
| Ford | ១៨៤៥.៨១១.០៤២. | ៨៧%២, | ៩៨៨៥២៩.៥៣៥. | ៨៦%១, |
| **ប្រតិបត្តិការផ្សេងទៀត** | ១៧២០១២.០៧៣. | ១៤%៤, | ១៧៨២១៤.៦៦០. | ១៥%៦, |
| **ការលុបបំបាត់សាជីវកម្ម** | (០៦០.៥៩២.១៩) | %៦,១- | (៣៨៩.៦១០.១៨) | %៦,១- |
| **សរុប** | ១៧៩៧.២៩២.១៩៥. | ១០០%០, | ១៣៥៤.៥៨៥.១៤៨. | ១០០%០, |

ចំណូលរបស់ Ford សម្រាប់ឆ្នាំ២០២០ បានកើនឡើងចំនួន ៥៤,២ ប៊ីលានរៀល (ធៀបនឹងឆ្នាំ២០១៩កើនឡើងចំនួន +៥,៥%) ដែលជាលទ្ធផលនៃភាពរឹងមាំនៃត្រីមាសទី១ និងត្រីមាសទី៤ ឆ្នាំ២០២០ ប៉ុន្តែចំណូលនេះ ត្រូវបានកាត់កងដោយការធ្លាក់ចុះនូវបរិមាណលក់ដែលមានចំនួនទាបនៅក្នុងត្រីមាសទី២ និង ត្រីមាសទី៣ នៃឆ្នាំ ២០២០ ដែលបណ្តាលមកពីផលប៉ះពាល់នៃវីរុសកូវីដ-១៩។ ចំណូលនៃប្រតិបត្តិការផ្សេងទៀតត្រូវបានថយចុះចំនួន ៦,៥ ប៊ីលានរៀល (ថយចុះ -៣,៧%ធៀបនឹងឆ្នាំ២០១៩) ដែលបណ្តាលមកពីផលប៉ះពាល់នៃវីរុសកូវីដ-១៩ ជាពិសេសក្នុងត្រីមាសទី២ ឆ្នាំ២០២០។

៣. គម្លាតចំណេញដុល

| គិតជាពាន់រៀល | ២០២០ | ២០១៩ | ចំនួនប្រែប្រួល | ភាគរយនៃការផ្លាស់ប្តូរ |
|---|---|---|---|---|
| **ចំណូលសរុប** | ១៧៩៧.២៩២.១៩៥. | ១៣៥៤.៥៨៥.១៨៨. | ៨៦៤៨៣.៧០៧. | *៤,១%* |
| **ចំណេញដុល** | ១៨៨២៣៩.៧៧៥. | ១៨៧៨៣៦.៩៥៣. | ៨២១៨០៣. | *០,៤%* |
| **គម្លាតចំណេញដុល** | *១៥,៨%* | *១៦,៤%* | | |

គម្លាតចំណេញដុលសម្រាប់ឆ្នាំ២០២០មានចំនួន ១៥,៨% ដែលទាបជាងគម្លាតចំណេញដុល ក្នុងឆ្នាំ ២០១៩ ចំនួន ១៦,៤% ដែលបណ្តាលមកពី ការប្រកួតប្រជែងក្នុងទីផ្សារនៅអំឡុងពេលកូវីត-១៩។

៤. ការវិភាគអំពីប្រាក់ចំណេញមុនបង់ពន្ធ (PBT)

| គិតជាពាន់រៀល | ២០២០ | ២០១៩ | ចំនួនប្រែប្រួល | ភាគរយនៃការផ្លាស់ប្តូរ |
|---|---|---|---|---|
| **ចំណូលសរុប** | ១៧៩៧.២៩២.១៩៥. | ១៣៥៤.៥៨៥.១៨៨. | ៨៦៤៨៣.៧០៧. | *៤,១%* |
| **ចំណេញដុល** | ១៨៨២៣៩.៧៧៥. | ១៨៧៨៣៦.៩៥៣. | ៨២១៨០៣. | *០,៤%* |
| **គម្លាតចំណេញដុល** | *១៥,៨%* | *១៦,៤%* | | |
| **ចំណាយ** | ៦៣៨៧៨.៣៩៥. | ៦៤៥២៨.៩៦១. | (៦៥០.៥៦៥.១) | *២-,៤%* |
| **ចំណាយហិរញ្ញវត្ថុ** | ១៤៦២៤.៧៧៧. | ៩៦៩០.៥៩៤. | ៥៩៣៤.១៨២. | *៥៤,០%* |
| **ប្រាក់ចំណេញមុនបង់ពន្ធ** | ១១០៧៣៧.៦០១. | ១១៣៦១៨.៣៩៧. | (៨៨១.៧៩៥.២) | *២-,៥%* |
| **គម្លាត** | *៩,៣%* | *៩,៩%* | | |

គម្លាតប្រាក់ចំណេញសរុបមុនបង់ពន្ធ ត្រូវបានថយចុះពី ៩,៩% ក្នុងឆ្នាំ២០១៩ មកនៅត្រឹម ៩,៣% ក្នុងឆ្នាំ ២០២០ ដែលសបញ្ជាក់ឲ្យឃើញពីធ្លាក់ចុះ (១៥,៨% ធៀបនឹង ១៦,៩% ឆ្នាំ២០១៩) ការធ្លាក់ចុះនៃការចំណាយ ចំនួន ១,៦ ប៊ីលានរៀលគឺដោយសារវិធានការបង់ពន្ធក្នុងឆ្នាំ២០១៩ ចំណែកឯហិរញ្ញវត្ថុដែលកើនឡើងចំនួន ៥,២ ប៊ីលានរៀលគឺដោយសារយុទ្ធសាស្ត្រកាត់បន្ថយចំណាយក្នុងអំឡុងពេលជម្ងឺរាតត្បាតកូវីដ-១៩។

៥. ការវិភាគអំពីប្រាក់ចំណេញក្រោយបង់ពន្ធ (PAT)

| គិតជាពាន់រៀល | ២០២០ | ២០១៩ | ចំនួនប្រែប្រួល | ភាគរយនៃការផ្លាស់ប្តូរ |
|---|---|---|---|---|
| **ប្រាក់ចំណេញមុនបង់ពន្ធ** | ១១០៧៣៦.៦០១. | ១១៣៦១៨.៣៩៧. | (៨៨២.៧៩៥.២) | *២-,៥%* |
| **ចំណាយពន្ធ** | ១៣៥៧៤.៥៤៣. | ២២៧៣៥.៧៦៨. | (១៦១.២២៥.៩) | *៤០-,៥%* |
| **ប្រាក់ចំណេញក្រោយបង់ពន្ធ** | ៩៧១៦៣.០៥៨. | ៩០៨៨៣.៦២៨. | ៦២៨០.៤២៩. | *៧-,១%* |
| **គម្លាតប្រាក់ចំណេញក្រោយបង់ពន្ធ** | *៨,១%* | *៧,៩%* | | |

គម្លាតប្រាក់ចំណេញក្រោយបង់ពន្ធក្នុងឆ្នាំ២០២០ មានចំនួន ៨,១% កើនឡើងពីចំនួន ៧,៩% ក្នុងឆ្នាំ ២០១៩ ដែលភាពច្រើនបណ្តាលមកពីការលើកទឹកចិត្តលើថ្លៃពន្ធចំនួន ៨,០ ប៊ីលានរៀលក្នុងឆ្នាំ ២០២០។

## ខ. កត្តាសំខាន់ៗដែលប៉ះពាល់ដល់ប្រាក់ចំណេញ

### ១. ការវិភាគអំពីតម្រូវការ និង ការផ្គត់ផ្គង់

ការរាតត្បាតនូវវីរុសកូវីដ-១៩ នៅក្នុងប្រទេសកម្ពុជាបានផ្តល់ផលប៉ះពាល់យ៉ាងខ្លាំងទាំងតម្រូវការ និង ការផ្គត់ផ្គង់ជាពិសេសនៅក្នុងដំណាច់ត្រីមាសទី២ ឆ្នាំ២០២០។

តម្រូវការ ត្រូវបានប៉ះពាល់តាមរយៈការពន្យារពេល និងការលុបចោលនូវគម្រោងឯកជន និងគម្រោងសាធារណៈធំៗ ការធ្លាក់ចុះនូវជំនឿទុកចិត្តរបស់អតិថិជន ការខាតបង់របស់អាជីវកម្មទេសចរណ៍ បដិសណ្ឋាកិច្ច និងភាពតឹងរឹងជាងមុនចំពោះកម្ចីធនាគារ។ ដោយនៅដំណាច់ត្រីមាសទី៤ វិស័យទេសចរណ៍ និងវេជ្ជសាស្ត្រគឺនៅតែទទួលផលប៉ះពាល់យ៉ាងខ្លាំងពីការរាតត្បាតនូវវីរុសកូវីដ-១៩ ។

ការផ្គត់ផ្គង់ ត្រូវបានប៉ះពាល់ដោយសារការបិទទីក្រុង ជាពិសេសរោងចក្រ Ford នៅប្រទេសថៃ ប៉ុន្តែបន្ទាប់មកទៀតក៏បានត្រលប់មករកភាពធម្មតាវិញនៅដើមត្រីមាសទី៣ ឆ្នាំ២០២០។

### ២. ការវិភាគអំពីការប្រែប្រួលនូវតម្លៃវត្ថុធាតុដើម

មិនមានការប្រែប្រួលសំខាន់លើតម្លៃនៃវត្ថុធាតុដើមឡើយ។ ប៉ុន្តែតម្លៃដឹកជញ្ជូនបានកើនឡើង ក្នុងកំឡុងការរាតត្បាតនៃមេរោគ កូវីត-១៩។

### ៣. ការវិភាគអំពីពន្ធដារ

<u>វិញ្ញាបនប័ត្រមាសនៃការអនុវត្តពន្ធ</u>

ក្រុមហ៊ុន RMAC បានទទួលវិញ្ញាបនបត្រមាសនៃការអនុវត្តពន្ធដែលមានសុពលភាព ២ ឆ្នាំ សម្រាប់ឆ្នាំជាប់ពន្ធ ២០២០ និង ២០២១ ក្នុងការទទួលស្គាល់ការអនុវត្តន៍ល្អរបស់ក្រុមហ៊ុនចំពោះច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារនៅកម្ពុជា។

<u>ការលើកទឹកចិត្តលើការអនុវត្តពន្ធ</u>

អនុលោមតាមអនុក្រឹត្យលេខ ០១ អ.ន.ក្រ បក ស្តីពីការលើកទឹកចិត្តពន្ធក្នុងវិស័យមូលបត្រ និងប្រកាសលេខ ១៨៣ ស្តីពីការអនុវត្តការលើកទឹកចិត្តពន្ធលើប្រាក់ចំណូលពន្ធសម្រាប់ក្រុមហ៊ុនដែលផ្តល់មូលបត្រជូនសាធារណៈជនដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់នឹងទទួលបានការលើកទឹកចិត្តពន្ធដូចខាងក្រោម ត្រូវមានការយល់ព្រមពីអាជ្ញាធរពាក់ព័ន្ធ៖

- អង្គភាពដែលចេញមូលបត្រកម្មសិទ្ធិច្រើនជាង ២០% នៃសិទ្ធិបោះឆ្នោត និង/ឬចេញមូលបត្របំណុលច្រើនជាង ២០% នៃទ្រព្យសកម្មសរុប និងមានកាលកំណត់យ៉ាងតិច ៧ ឆ្នាំនឹងទទួលបានការលើកទឹកចិត្តពន្ធ ៥០% លើពន្ធលើប្រាក់ចំណូលសម្រាប់ រយៈពេល ៣ ឆ្នាំ។
- អង្គភាពដែលចេញមូលបត្រកម្មសិទ្ធិ ២០% និង/ឬតិចជាងសិទ្ធិបោះឆ្នោត និង/ឬបោះផ្សាយមូលបត្របំណុល ២០% និង/ឬតិចជាងទ្រព្យសកម្មសរុបរបស់ខ្លួននឹងទទួលបានការលើកទឹកចិត្តពន្ធលើពន្ធលើប្រាក់ចំណូលក្នុងរយៈពេល ៣ ឆ្នាំដោយផ្អែកលើមូលដ្ឋានសមាមាត្រ។ ការលើកទឹកចិត្តពន្ធទាំងនេះត្រូវ

បានកំណត់ត្រឹម ២០.០០០.០០០.០០០ រៀល និង ៨.០០០.០០០.០០០ រៀលសម្រាប់អ្នកចេញមូលបត្រកម្មសិទ្ធិ និងមូលប័ត្របំណុលតរៀងៗគ្នា។

គិតមកត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមហ៊ុន RMAC បានទទួលការបញ្ជាក់ពីគណៈកម្មការមូលបត្រកម្ពុជា (គ.ម.ក.) និងអគ្គនាយកដ្ឋានពន្ធដារ ("GDT") ក្នុងការស្នើសុំការលើកទឹកចិត្តពន្ធដែលមានចំនួនអតិបរមា ៨.០០០.០០០.០០០ រៀល សម្រាប់ពន្ធនេះ នៃឆ្នាំ ២០២០ ដូចឆ្នាំទី ១ ។

របាយការណ៍ហិរញ្ញវត្ថុឆ្នាំ ២០២០ ជាកត្តាលើកទឹកចិត្តដល់ការអនុវត្តពន្ធចំនួន ៨.០០០.០០០.០០០ រៀល ដែលទាក់ទងនឹងឆ្នាំទី ១ ។

ថ្មីៗនេះមិនមានការផ្លាស់ប្តូរគួរឱ្យកត់សម្គាល់នៅក្នុងបទប្បញ្ញត្តិពន្ធនៅក្នុងប្រទេសកម្ពុជាដែលមានឥទ្ធិពលប៉ះពាល់ទៅលើដំណើរការហិរញ្ញវត្ថុរបស់យើងទេ។

## ៤. ការវិភាគអំពីទំនិញលើកលែង និងទំនិញពិសេស

មិនមានទំនិញលើកលែង និងទំនិញពិសេសក្នុងអំឡុងពេលនេះឡើយ។

## គ. ការផ្លាស់ប្តូរសំខាន់ៗពាក់ព័ន្ធនឹងការលក់ និងចំណូល

ចំណូលសម្រាប់ត្រីមាសទី៤ ឆ្នាំ២០២០ និងក្នុងរយៈពេលពេញមួយឆ្នាំ ២០២០ និង ប្រៀបធៀបរយៈពេលនេះជាមួយនឹងឆ្នាំ ២០១៩ ត្រូវបានបង្ហាញក្នុងឯកសារនេះ និងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេប។

## ឃ. ផលប៉ះពាល់នៃអត្រាប្តូរប្រាក់ អត្រាការប្រាក់ និងតម្លៃទំនិញ

ការប្រែប្រួលអត្រាប្តូរប្រាក់ មិនមានការប៉ះពាល់ចំបងណាមួយដល់ដំណើរការផ្នែកហិរញ្ញវត្ថុរបស់ក្រុមហ៊ុនឡើយ ដោយហេតុថាអាជីវកម្មមួយចំនួនធំរបស់ក្រុមហ៊ុនត្រូវបានធ្វើឡើងជាប្រាក់រៀល/ប្រាក់ដុល្លារអាមេរិក ភ្ជាប់ជាមួយនឹងការបញ្ជាទិញនូវផលិតផលនាំចូលតិចតួចប៉ុណ្ណោះដែលធ្វើឡើងជារូបិយបណ្ណបរទេស។ ក្រុមហ៊ុន មិនបានទទួលរងផលប៉ះពាល់ដោយតម្លៃទំនិញ ដោយសារក្រុមហ៊ុនមិនបានធ្វើការដោះដូរទំនិញឡើយ។ អត្រាការប្រាក់មានការប្រែប្រួលបន្តិចបន្តួចតែប៉ុណ្ណោះក្នុងអំឡុងពេលនេះ។

## ង. ផលប៉ះពាល់នៃអតិផរណា

មិនមានផលប៉ះពាល់ចំបងណាមួយនៃអតិផរណា ដែលបានប៉ះពាល់ដល់ដំណើរការផ្នែកហិរញ្ញវត្ថុរបស់ក្រុមហ៊ុនឡើយ។

## ច. គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុរបស់រាជរដ្ឋាភិបាល

មិនមានផលប៉ះពាល់ចំបងណាមួយដែលបណ្តាលមកពីការប្រែប្រួលនូវគោលនយោបាយរបស់រាជរដ្ឋាភិបាលឡើយ ក្រៅពីគោលនយោបាយដែលពាក់ព័ន្ធនឹងវីរុសកូវីដ-១៩ ដែលរួមមានការកាត់បន្ថយចំណាយរដ្ឋ និងការរឹតត្បឹតលើវិស័យមួយចំនួនដល់សេដ្ឋកិច្ចជាតិ ដូចជាវិស័យទេសចរណ៍។

## ហត្ថលេខារបស់អភិបាលរបស់ក្រុមហ៊ុនបោះផ្សាយ

កាលបរិច្ឆេទ៖ ៣០ មីនា ឆ្នាំ២០២១

ព្រះរាជាណាចក្រកម្ពុជា
ក្រុមហ៊ុន
អ អិម អេ (ខេមបូឌា) ឯ.ក
R M A (CAMBODIA) PLC.
KINGDOM OF CAMBODIA

កាលបរិច្ឆេទ៖ ៣០ មីនា ឆ្នាំ២០២១
បានអាន និង អនុម័តដោយ:

..........................................
ហត្ថលេខា
ឈ្មោះ៖ លោក Kevin Whitcraft
តំណែង៖ ប្រធានក្រុមប្រឹក្សាភិបាល

កាលបរិច្ឆេទ៖ ៣០ មីនា ឆ្នាំ២០២១
បានអាន និង អនុម័តដោយ:

..........................................
ហត្ថលេខា
ឈ្មោះ៖ លោក Thomas Arthur Whitcraft
តំណែង៖ អភិបាលមិនប្រតិបត្តិ

កាលបរិច្ឆេទ៖ ៣០ មីនា ឆ្នាំ២០២១
បានអាន និង អនុម័តដោយ:

..........................................
ហត្ថលេខា
ឈ្មោះ៖ លោក ងន សាំង
តំណែង៖ អភិបាលប្រតិបត្តិ និងជានាយកប្រតិបត្តិ

កាលបរិច្ឆេទ៖ ៣០ មីនា ឆ្នាំ២០២១
បានអាន និង អនុម័តដោយ:

..........................................
ហត្ថលេខា
ឈ្មោះ៖ លោក Christopher Gowen Manley
តំណែង៖ អភិបាលមិនប្រតិបត្តិ

កាលបរិច្ឆេទ៖ ៣០ មីនា ឆ្នាំ២០២១
បានអាន និង អនុម័តដោយ:

..........................................
ហត្ថលេខា
ឈ្មោះ៖ លោក Vichit Ith
តំណែង៖ អភិបាលឯករាជ្យ

